# ការធ្វើដំណើរពីភូមិខ្ញុំទៅកាន់ទីក្រុង

គេច្រើនធ្វើដំណើរពីភ្នំពេញ ទៅភូមិស្នាយពល តាមទោចក្រយាន ឬ ទោចក្រយានយន្តដែលត្រូវចំណាយពេលអស់ជាងកន្លះថ្ងៃ ។ ប៉ុន្តែទោះជាមានការលំបាកយ៉ាងណាក្តី អ្នកស្រុកភូមិខ្ញុំនិយមធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញជាងធ្វើដំណើរទៅកាន់ទីរួមខេត្តព្រៃវែង ដែលមានចំងាយប្រហែលតែ ៣០ គីឡូម៉ែត្រប៉ុណ្ណោះ ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០-៧០ ផ្លូវពីស្នាយពល ទៅទីរួមខេត្តព្រៃវែងនៅតែមានការលំបាកនៅឡើយ ហើយទទួលរងនូវការខូចខាតជាញឹកញាប់ដោយសារទឹកជំនន់ ។ អ្នកភូមិយើងតែងធ្វើដំណើរតាមផ្លូវថ្នល់ នៅរដូវប្រាំងដែលចាប់ផ្តើមពីខែ វិច្ឆិកា ទៅខែ ឧសភា ។

ក្នុងសម័យនោះ មានរថយន្តឈ្នួលដឹកអ្នកដំណើរពីស្នាយពល ទៅទីរួមខេត្តព្រៃវែងចំនួនពីរគ្រឿង ។ រថយន្តមួយពណ៌ក្រហម អ្នកស្រុកច្រើនហៅថាឡានក្រហម ឬ អាក្រហម ។ រថយន្តមួយទៀតពណ៌ខៀវ គេហៅថាឡានខៀវ ឬ អាខៀវ ។ ថៅកែឡានឈ្នួលនេះជាជនជាតិវៀតណាមកាត់ចិន ។ អ្នកស្រុក ហៅថាថៅកែថាក់ ឬ ចិកថាក់ចំពោះឡានខៀវ និង ថៅកែស៊ុង ឬ ចិកស៊ុងចំពោះឡានក្រហម ។ ការធ្វើដំណើរចម្ងាយសាមសិបគីឡូម៉ែត្រពីស្នាយពលទៅទីរួមខេត្តព្រៃវែង ត្រូវប្រើពេល ៣ ទៅ ៤ ម៉ោង ។ តាមផ្លូវ រថយន្តឈ្នួលត្រូវឈប់ជាញឹកញាប់ ដើម្បីដាក់អ្នកដំណើរ ឬ ដាក់ទំនិញផ្សេងៗរួមទាំងបន្លែ ផ្លែឈើ ឬ សត្វជ្រូក មាន់ ទា ទៀតផង ។

នៅតាមផ្លូវ គេឃើញវាលស្រែវែងឆ្ងាយ ដែលមានដើមត្នោតរាប់ពាន់ដើមដុះច្រូងច្រាងតាមភ្លឺរាប់គីឡូម៉ែត្រ ។ ជារឿយៗនៅពេលធ្វើដំណើរ ជួនកាលគេត្រូវចុះដើរទាំងអស់គ្នា ដើម្បីជួយសម្រាលទម្ងន់រថយន្ត នៅពេលណាដែលត្រូវឆ្លងអូរ ឬ ប្រឡាយទឹកម្តងៗ បើពុំនោះទេរថយន្តអាចត្រូវជាប់គាំង ។ អ្នកដំណើរទាំងនោះត្រូវជួយរុញរថយន្តផងក៏មាន ។ នៅពេលឆ្លងកាត់ភូមិនីមួយៗ ជាពិសេសត្រង់ម្តុំភូមិព្រៃញ្ញៅ ពួកក្មេងតូចៗទាំងខ្លួនទទេរត់ប្រដេញគ្នា តាមពីក្រោយរថយន្ត ស្រែកហ៊ោរកញ្ជ្រៀវយ៉ាងសប្បាយ ក្នុងធូលីដីដែលហុយសំពោង ។ ក្មេងៗខ្លះរត់លោតតោងឈរនៅខាងក្រោយរថយន្ត អស់មួយស្របក់យ៉ាងរីករាយ ។ ខ្លួនប្រាណក្បាល មុខ មាត់របស់ពួកគេប្រឡាក់ប្រឡូសដោយធូលីសសំព្រុស នាំឲ្យមើលមិនស្គាល់ ។ ផ្លូវថ្នល់ទៅកាន់ទីរួមខេត្តនោះត្រូវបាន គេបររទេះគោ ឬ ក្របីពីលើទៀត

ផង ។

ផ្លូវពីស្វាយពល ទៅភ្នំពេញ ក៏មិនខុសគ្នាប៉ុន្មានដែរ ។ ក៏ប៉ុន្តែនៅសម័យនោះ ពុំមានរថយន្តចេញចូល ឬ ប្រើប្រាស់នៅឡើយទេ ។ ផ្លូវនោះជាផ្លូវតូចតាចដែលអ្នកជិះទោចក្រយានអាចធ្វើដំណើរបានដោយស្រួលផង អាចឈប់សំរាកស្រស់ស្រូបចំណីអាហារ ឬ ភេសជ្ជៈផង ដែលគេដាក់លក់តាមផ្លូវ ហូរហែជាប់រហូតមិនដូចផ្លូវពីស្វាយពល ទៅព្រៃវែងទេ ។ ផ្លូវពីស្វាយពល ទៅភ្នំពេញ[3]ត្រូវឆ្លងកាត់ទន្លេ និង ព្រែកជាច្រើន ជាពិសេស ឆ្លងកាត់ទន្លេតូចតាមស្ពានឫស្សីមួយ ។ ស្ពាននេះរលាស់ចុះឡើង នៅពេលគេដើរឆ្លងកាត់ម្តងៗ ។ ផ្លូវនេះនាំរហូតដល់ទន្លេធំ ឬ ទន្លេមេគង្គ នៅក្នុងខេត្តកណ្តាល ។ ម្យ៉ាងទៀត គេត្រូវឆ្លងកាត់ព្រៃស្លុបយ៉ាងវែងចាប់ពីភូមិកំពង់ចម្លង ភូមិព្រៃបាំង រហូតដល់ភូមិព្រះវិហារសួគ៌ ។ នៅពេលគេមកដល់ព្រែកតាមាក់ អ្នកដំណើរត្រូវឡើងកប៉ាល់បន្តដំណើរឆ្ពោះទៅភ្នំពេញ ។

នៅរដូវវស្សា ទាំងផ្លូវពីស្វាយពល ទៅទីរួមខេត្តព្រៃវែង ទាំងផ្លូវទៅភ្នំពេញ មិនអាចធ្វើចរាចរណ៍បានឡើយ ដោយហេតុមានទឹកជំនន់ឡើងលិច ក្នុងរយៈពេលពីបីទៅបួនខែគឺ ពីខែ សីហា ទៅខែ វិច្ឆិកា ។ នៅពេលនោះ អ្នកស្រុកភូមិខ្ញុំធ្វើដំណើរតាមផ្លូវទឹក ។ ក្នុងសម័យនោះ មានតែពាណិជ្ជករពីរ ឬ បីនាក់ទេ ដែលប្រកបអាជីវកម្មដឹកជញ្ជូនតាមផ្លូវទឹកនេះ ។

កាណូតដឹកអ្នកដំណើរ និង ទំនិញត្រូវចំណាយពេលកន្លះថ្ងៃ ឬ ពេញមួយថ្ងៃ មុននឹងទៅដល់ទីក្រុងភ្នំពេញ អាស្រ័យដោយស្ថានភាពទឹកជំនន់គឺ ទឹកឡើង ឬ ទឹកស្រក ។ ការធ្វើដំណើរតាមកាណូតអាចធ្វើឲ្យកើតក្តីមនោរម្យក្នុងអារម្មណ៍ខ្លាំងណាស់ដោយសារទេសភាពធម្មជាតិគួរជាទីគាប់ភ្នែកដែលយើងឆ្លងកាត់ ។ ជាពិសេស នៅពេលដែលយើងទទួលទានអាហារម្តងៗ ម្ហូបដ៏ឆ្ងាញ់ពិសារបស់យើង

---

[3] ផ្លូវនេះសព្វថ្ងៃ បានក្លាយជាកំណាត់មួយនៃផ្លូវជាតិលេខ៨ ដែលត្រូវបានពង្រីក និង ក្រាលកៅស៊ូយ៉ាងល្អស្អាត ។

ជាម្ហូបដ៏សាមញ្ញៗដូចជា៖ បាយខ្ទប់ស្លឹកឈូកជាមួយម៉ាំល្ហុង ឬ ជាមួយត្រីងៀតដុត ជាដើម ។ តាមកាណូត យើងអាចមើលឃើញទំហំទឹកល្ហល្ហេវវែងឆ្ងាយ ធំទូលាយ ដែលគួរឲ្យស្រមៃថា យើងកំពុងធ្វើដំណើរនៅក្នុងមហាសមុទ្រ ។ ពីខែ កញ្ញា ទៅខែ តុលា កំពស់ទឹកឡើងខ្ពស់ កន្លែងខ្លះខ្ពស់ស្មើរផុតចុងត្នោត ធ្វើឲ្យយើងមើលឃើញ ផ្ទៃទឹកនៅជាប់នឹងជើងមេឃ ។ នៅកន្លែងខ្លះ ទឹកឡើង លិចដល់ដំបូលផ្ទះ ។ នៅពេលធ្វើដំណើរ គេអាចប្រទះឃើញពពួកសត្វស្លាបចំរុះពណ៌ ហើររំលងយើង ទាំងហ្វូងៗ ឬ ហែលលេងនៅក្បែរៗយើង ជាពិសេស ពួកសត្វទុងធំៗ ។ ត្រីក៏ សម្បូណ៌ណាស់ដែរ ។ នៅរដូវទឹកស្រក តាមព្រែកនានា ពេលណាកាណូតយើង ឆ្លងកាត់ ត្រីខ្លះលោតចេញពីទឹកផ្លោតចុះផ្លោតឡើង គួរឲ្យចង់ចុះទៅចាប់ ។ កាលសម័យនោះ យើងមិនទាន់ស្គាល់និយមន័យនៃពាក្យអេកូឡូស៊ី (Ecology) នៅឡើយទេ ។ នៅពេលទឹកស្រកខ្លាំង កាណូតបើកយឺតៗព្រោះត្រូវគេចជៀសមែកឈើតូចធំ នៅតាមមាត់ទឹកកុំឲ្យវាត់មកត្រូវអ្នកដំណើរ ។